## បង្កើតហើយរក្សាប្រវត្តិដ៏ល្អ នៃការជំពាក់លុយ (2009)

គឺជាដំណើរហេតុដែលបញ្ជាក់ពីប្រវត្តិ នៃការខ្ចីប្រាក់ ពីរបាយការណ៍ នៃការជំពាក់លុយ ធ្វើដូចម្ដេច ដើម្បីឲ្យបានរបាយការណ៍ នៃការជំពាក់លុយ ធ្វើយ៉ាងដូចម្ដេចដើម្បីអាចបានប្រវត្តិដ៏ល្អ ហើយតើត្រូវតវ៉ារបៀបណា បើសិនជាមានបញ្ហា ។

# មាតិការឿង


*អ្វីទៅជាប្រវត្តិ នៃការជំពាក់លុយ

*ប្រវត្តិល្អ ប្រឆាំង នឹងប្រវត្តិអាក្រក់

*អ្វីទៅជារបាយការណ៍ នៃការជំពាក់លុយនោះ ?

*ធ្វើយ៉ាងណាដើម្បីឲ្យបានរបាយការណ៍ នៃការជំពាក់លុយ

*ម៉េចបានជាការសុំខ្ចីលុយរបស់ខ្ញុំបានត្រូវគេបដិសេធ

*តើត្រូវធ្វើយ៉ាងណា បើការសុំខ្ចីលុយរបស់ខ្ញុំបានត្រូវគេបដិសេធ

*ធ្វើយ៉ាងណា ដើម្បីសាងប្រវត្តិខ្ចីលុយឲ្យបានល្អ

*ប័ណ្ណខ្ចីលុយគ្មានការធានា

*សេវានៃប័ណ្ណខ្ចីលុយ ដែលអាចជ្រើសរើសបាន

*សិទ្ធិរបស់លោកអ្នក

*តើត្រូវតវ៉ាតាមរយៈណា


## អ្វីទៅជាប្រវត្តិ នៃការជំពាក់លុយ

ពេលលោកអ្នកសុំខ្ចីលុយ ឬដាក់ពាក្យសុំប័ណ្ណខ្ចីលុយ ម្ចាស់លុយ នឹងពិនិត្យមើលប្រវត្តិ នៃការជំពាក់លុយ ដើម្បីឲ្យដឹងថា តើលោកអ្នកមានលទ្ធភាព នឹងសងលុយ ឬសងជំពាក់គេទេ ។

បើលោកអ្នកមិនដែលខ្ចីលុយគេ ដូចជាមិនដែលមានប័ណ្ណខ្ចីលុយ គ្មានកុងក្នុងហាងលក់ទំនិញ ទិញឡាន ឬផ្ទះមិនបាន លោកអ្នកប្រាកដជាគ្មាន ប្រវត្តិ

នៃការជំពាក់លុយហើយ ។

## ប្រវត្តិល្អអាចជួយលោកអ្នក

*ទិញផ្ទះ

*មានការងារ

*ដាក់ទូរស័ព្ទ មានភ្លើងបំភ្លឺ និងភ្លើងកំដៅទឹក

*ជួលបន្ទប់

*ទិញសម្ភារៈធំៗ ( តុ ទូ ប្រដាប់ប្រើប្រាស់ ក្នុងផ្ទះ )

*ដោយមិនបាច់ចាយលុយសុទ្ធ

*ខ្ចីលុយទិញឡាន

*អាចទិញការធានារ៉ាប់រងបាន

*ខ្ចីលុយបាន

*មានប័ណ្ណខ្ចីលុយ

## ប្រវត្តិជំពាក់ល្អផ្ទុយ និងប្រវត្តិមិនល្អ

បើលោកអ្នកធ្លាប់មានប័ណ្ណខ្ចីលុយ ហើយធ្លាប់ខ្ចីលុយ ហើយបានសងតាមពេលកំណត់ លោកអ្នកប្រាកដជាមានប្រវត្តិល្អហើយ ។ កំណត់ហេតុ ពីប្រវត្តិជំពាក់លុយល្អ បានមកពីការចាយប្រាក់ ដែលខ្ចីគេនោះដោយប្រយ័ត្ន ។

## អ្នកដែលមានប្រវត្តិជំពាក់លុយល្អ

មានប្រវត្តិល្អ ខ្ចីលុយបានហើយប្រើប័ណ្ណខ្ចីលុយបាន

មានកំណត់ហេតុថា យ៉ាងហោចណាស់ ក៏បានបង់ក្នុងចំនួនយ៉ាងតិចទៀងទាត់ពេលតាមថ្ងៃដែលគេកំណត់ ហើយមិនប្រើលុយឲ្យហួសពីចំនួនដែលគេអនុញ្ញាតិឲ្យប្រើ ។ យកតែចំនួនប្រាក់ជំពាក់ ឬប័ណ្ណខ្ចីលុយណាដែលអាចមានលទ្ធភាពនឹងសង វិញ ( កុំខ្ចីច្រើន សុំខ្ចីត្រឹមតែចំនួនដែលអាចសងគេបាន ) ។

**ប្រវត្តិជំពាក់លុយអាក្រក់ បណ្តាលមកពីមិនសងលុយទៅគេវិញ តាមកាលកំណត់ដែលសន្យា ។**

**ប្រវត្តិជំពាក់លុយមិនល្អ បណ្តាលមកពី:**

*សងយឺតពេល

*សងតិចជាងចំនួនដែលតំរូវឲ្យសង

*មានប័ណ្ណខ្ចីលុយច្រើនពេក ហើយជំពាក់គេច្រើនទោះជាសងគេទៀងទាត់តាម កាលកំណត់ក្តី

*ជំពាក់គេមិនសង ត្រូវគេដាក់ទៅភ្នាក់ងារទារលុយ

*ធ្វើជំនួញខាតរលំ

*មានដីការពីតុលាការឲ្យដកលុយពីប្រាក់ខែ ដើម្បីសងបំណុល

**អ្វីទៅជារបាយការណ៍ នៃប្រវត្តិជំពាក់លុយ**

របាយការណ៍ នៃប្រវត្តិជំពាក់លុយ គឺជាកំណត់ហេតុនៃការខ្ចីលុយ ប័ណ្ណខ្ចីលុយ ការសងលុយ និងបំណុលដែលនៅជំពាក់គេ ។ ពត៌មានទាំងនេះបានមកពីក្រុមហ៊ុនដែលឲ្យលោកអ្នកខ្ចីលុយ គឺម្ចាស់លុយ ។

ម្ចាស់លុយផ្តល់របាយការណ៍ ពីប្រវត្តិនៃការជំពាក់លុយរបស់លោកអ្នកទៅឲ្យក្រុមហ៊ុនមួយមានឈ្មោះថា **Credit Reporting bureau** ។ ក្រុមហ៊ុនទាំងនេះប្រកបរបរ ដោយប្រមូលពត៌មាន នៃអ្នកប្រើប្រាស់ពីម្ចាស់លុយ (ដូចជាធនាគារ ការឲ្យខ្ចីលុយ) **Credits Unions** ក្រុមហ៊ុនឲ្យខ្ចីលុយ ហើយនិងហាងលក់ទំនិញ ។ **Credit Reporting bureau** រក្សាពត៌មានទុកក្នុងមូលដ្ឋានទិន្នន័យ នៃកំព្យូទ័រ ហើយផ្តល់ទៅឲ្យម្ចាស់លុយពេលណាលោកអ្នកដាក់ពាក្យសុំខ្ចីលុយ ឬសុំប័ណ្ណខ្ចីលុយថ្មី ។

**Credit Reporting bureau** មិនធ្វើការសំរេចពីរឿងឲ្យខ្ចីលុយទេ ។

ពេលណាដែលលោកអ្នកដាក់ពាក្យសុំប័ណ្ណខ្ចីលុយ ឬសុំខ្ចីលុយ ម្ចាស់លុយយក របាយការណ៍នៃការជំពាក់លុយនេះមកសំរេចថាតើលោកអ្នកមានការទទួលខុសត្រូវគ្រប់គ្រាន់ ដើម្បីដោះស្រាយលុយជំពាក់ថ្មីបានទេ ។

**នៅក្នុងរបាយការណ៍ នៃការជំពាក់លុយមាន**

*ពត៌មាននៃការសងលុយពីពេលមុន និងពេលបច្ចុប្បន្ន

*តើសងគេតាមពេលកំ ណត់ ឬក៏យឺត

*លុយដែលសល់នៅជំពាក់គេ ជំពាក់ប័ណ្ណខ្ចីលុយចំនួនប្រាក់ជំពាក់គេដែលនៅសល់

*ពត៌មានអំពីលោកអ្នក ដែលបានមកពីកំណត់ហេតុជាឯកជនដូចជាធ្វើជំនួញខាតរលំ ឬជំពាក់លុយបង់តាក់មិនទាន់សង ។

*ជំពាក់ថ្លៃចិញ្ចឹមកូន

*ឈ្មោះមនុស្សដែលសុំលិខិតចម្លងច្បាប់នេះ ( ការស៊ើបអង្កេត ) ក្នុងពេលថ្មីៗ

**របាយការណ៍នៃការជំពាក់លុយគ្មាន**

ពត៌មានអំពីជាតិកំណើតរបស់លោកអ្នក សាសនា ស្ថានភាពនយោបាយ ប្រវត្តិសុខភាព ជីវិតរស់នៅ សារតាឬកំណត់ហេតុ នៃឧក្រិដ្ឋកម្មឡើយ ។

**តើខ្ញុំអាចបានរបាយការណ៍ នៃការជំពាក់លុយតាមរបៀបណា ?**

តាមច្បាប់នៃសហព័ន្ធ ជារៀងរាល់ឆ្នាំ លោកអ្នកអាចបានទទួលសំបុត្រចម្លងឥតគិតថ្លៃតាមរយៈក្រុមហ៊ុនធំៗ ចំនួន៣គឺ

**Experian: 888 - 397 - 3742 www.Experian.com**
**Equifax: 800 – 685 – 1111 www.Equifax.com**
**TransUnion: 800 – 916 – 8800 www.Transunion.com**

ក្រុមហ៊ុនទាំង៣នេះបានបង្កើត “Annual Credit Report “site (www.

Annualcreditreport.com) សំរាប់លោកអ្នកស្របតាមច្បាប់ នៃសហព័ន្ធ ។ លោកអ្នកអាចសុំរបាយការណ៍ Online, ដោយទូរស័ព្ទទៅលេខ 877-322-8228 ឬតាម mail ។ តាម mail លោកអ្នកត្រូវរក website ហើយរក order form
ហើយផ្ញើទៅអស័យដ្ឋាននៅក្នុង Website ។
លោកអ្នកមានសិទ្ធិ នឹងទទួលរបាយការណ៍ជំពាក់លុយជារៀងរាល់ឆ្នាំដោយមិនបាច់បង់ថ្លៃពីក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនទាំង៣ ។ លោកអ្នកអាចសុំរបាយការណ៍ទាំង៣ក្នុងពេលជាមួយគ្នា ឬក៏ក្នុងពេលបន្តបន្ទាប់គ្នា ។ ការសុំរបាយការណ៍ក្នុងពេលខុសៗ គ្នា ក្នុងរវាងមួយឆ្នាំអាចធ្វើឲ្យលោកអ្នកមានពេលនឹងត្រួតពិនិត្យជាញឹកញយ ដោយមិនបាច់ចំណាយលុយ ក្នុងការសុំរបាយការណ៍បន្ថែមទៀត ។
លោកអ្នកត្រូវផ្តល់ពត៌មានទៅ Credit **bureaus** ដើម្បីឲ្យគេស្គាល់គឺមាន

*នាមត្រកូល នាមខ្លួនឈ្មោះកណ្តាល ឬក៏ឈ្មោះបន្ថែមដូចជា Jr., Sr., ឬIII

*អាស័យដ្ឋានបច្ចុប្បន្ន ឬពីមុនក្នុងរវាង 2ទៅ5 ឆ្នាំតាមដែលគេត្រូវការ ។

*លេខសំគាល់ខ្លួន

*ថ្ងៃ ខែ ឆ្នាំ កំណើត

*និយោជកបច្ចុប្បន្ន

*លេខទូរស័ព្ទ

បើលោកអ្នកត្រូវបានគេបដិសេធ មិនឲ្យខ្ចីលុយក្នុងរវាង 60ថ្ងៃដោយសារតែមានឈ្មោះមិនល្អក្នុងរបាយការណ៍ នៃការជំពាក់លុយ ឬក៏ជាជនរងគ្រោះពីការកេងបន្លំនោះ លោកអ្នកមិនបាច់បង់លុយក្នុងការសុំរបាយការណ៍នោះទេ ។

**ម៉េចបានជាគេបដិសេធខ្ញុំ ?**

មនុស្សភាគច្រើនដែលសុំខ្ចីលុយត្រូវបានបដិសេធ ។ បើមានការយ៉ាងនេះម្ចាស់លុយត្រូវប្រាប់ថាម៉េចបានជា លោកអ្នកត្រូវគេបដិសេធ ។ ក្នុងករណីភាគច្រើន ការបដិសេធ គឺជាការសំអាងមួយដែលចែងឡើងក្នុងផ្នែកនេះ ។

**លោកអ្នកគ្មានប្រវត្តិជំពាក់លុយ**

បើលោកអ្នកមិនធ្លាប់ ជំពាក់គេ ឬក៏ទើប និងប្រើ Credit ឬក៏មិនធ្លាប់ប្រើ Credit ក្នុងពេលថ្មី ៗម្ចាស់លុយអាចជាបដិសេធ ព្រោះលោកអ្នកមិនទាន់មានប្រវត្តិក្នុងការជំពាក់លុយ ។ ព្រោះតែគ្មានពត៌មាននេះម្ចាស់លុយមិនអាច និងដឹងថាតើលោកអ្នកអាចសងលុយវិញបានត្រឹមត្រូវឡើយ ។ បើលោកអ្នកមិនដែលមាន Credit ទាល់តែសោះ ឬមិនដែលប្រើ Credit នេះអស់រយៈពេលដ៏យូរ លោកអ្នកអាចចាប់ផ្តើមសាងប្រវត្តិជំពាក់លុយបាន ។

**លោកអ្នកជំពាក់គេច្រើនណាស់**

ម្ចាស់លុយមានការស្ទាក់ស្ទើរ និងឲ្យលោកអ្នកខ្ចីលុយជាថ្មី បើសិនជាលោកអ្នកជំពាក់គេច្រើនពេក ។ ពេលម្ចាស់លុយផ្ទៀងផ្ទាត់សំណុំរឿងខ្ចីលុយ គេត្រូវមើលប្រាក់ចំណូល មើលប្រាក់ដែលអាចចាយបានហើយនឹងបំណុលដែលត្រូវសងដើម្បីសំរេចថា លោកអ្នកអាចសងគេបានប៉ុណ្ណាដែរ ។ ម្ចាស់លុយតែងគិតទៅឆាកដែលអាក្រក់បំផុត - បើលោកអ្នកចាយលុយដល់កំរិតខ្ពស់ដែលគេកំរិតឲ្យនោះ តើប្រាក់ចំណូលរបស់លោកអ្នកអាចគ្របដណ្តប់ប្រាក់ចំណាយបានទេ **?** បើចម្លើយថាទេ ពាក្យសុំខ្ចីលុយនោះប្រាកដជាត្រូវគេបដិសេធហើយ ។

**លោកអ្នកគ្មានការទទួលខុសត្រូវក្នុងការសងជំពាក់គេ**លោកអ្នកធ្លាប់បានទទួលលុយដែលខ្ចីគេ ប៉ុន្តែមិនចេះប្រើប្រាស់ដោយត្រឹមត្រូវ បើលោកអ្នកសងគេយឺតពេល ឬមិនសងជំពាក់គេ ឬមានការរកស៊ីខាត ដួលរលំ ម្ចាស់លុយមិនចង់ឲ្យប័ណ្ណខ្ចីលុយថ្មី ឬឲ្យលោកអ្នកខ្ចីលុយឡើយ ។ ដើម្បីឲ្យប្រវត្តិជំពាក់លុយរបស់

លោកអ្នកបានល្អប្រសើរឡើងវិញ លោកអ្នកត្រូវជំរះរឿងបំណុលចាស់ហើយ ចាប់ផ្តើមសងគេឲ្យទៀងទាត់ជារៀងរាល់ខែ ជូនដល់ទៅរាប់ឆ្នាំដើម្បីយកប្រវត្តិជំពាក់លុយល្អមកវិញ ។

## លោកអ្នកជាជនរងគ្រោះពីបទកេងបន្លំ

មនុស្សមិនទៀងត្រង់ខ្លះអាចធ្វើឲ្យខូច Credit របស់លោកអ្នកដោយយកឈ្មោះទៅប្រើ នេះថាការលួចបន្លំឈ្មោះ ។ ជនខ្លះដឹងថាខ្លួនឯងជាជនរងគ្រោះបន្ទាប់ពីគេបដិសេធមិនឲ្យខ្ចីលុយ ។ លោកអ្នកមិនមែនជាអ្នកទទួលខុសត្រូវទេ ក៏ប៉ុន្តែជាការពិបាក នឹងបញ្ជាក់ថា លោកអ្នកមានឈ្មោះល្អ រហូតទាល់តែលោកអ្នកស្តារឈ្មោះឲ្យបានល្អឡើងវិញ ។

មធ្យោបាយតែមួយដែលការពារពីការក្លែងបន្លំឈ្មោះ និងក្លែងបន្លំ Credit គឺត្រូវពិនិត្យឆែកឆេររបាយការណ៍ជំពាក់លុយយ៉ាងតិចមួយឆ្នាំម្តង ។ បើឃើញចំនួនប្រាក់ខ្លះដែលមិនស្គាល់ត្រូវទូរស័ព្ទទៅ Credit bureau ខាងផ្នែកពិនិត្យការលួចបន្លំឈ្មោះជាប្រញាប់ ។ ដើម្បីការពារការលួចបន្លំឈ្មោះត្រូវតែពិនិត្យមើលគ្រប់ប័ណ្ណខ្ចីលុយ និងគ្រប់បញ្ជីទារលុយ ។

## តើត្រូវធ្វើយ៉ាងណា បើការសុំខ្ចីលុយរបស់ខ្ញុំត្រូវគេបដិសេធនោះ ?

ការពន្យល់របស់ម្ចាស់លុយ ថាហេតុអ្វីបានជាការសុំខ្ចីលុយត្រូវបានគេបដិសេធ និងប្រាប់ថាគេបានទទួលសេចក្តីរាយការណ៍ពី Credit Reporting bureau មួយ បើលោកអ្នកត្រូវគេបដិសេធ លោកមានសិទ្ធិ នឹងបានទទួលសំបុត្រចម្លងមួយច្បាប់ដោយមិនបាច់បង់លុយក្នុងរយៈ 60ថ្ងៃ ។ ត្រូវទាក់ទងនឹង Credit Reporting Company តាមរយៈទូរស័ព្ទដើម្បីឲ្យបានសំបុត្រចម្លងនេះ ។

ប៉ុន្តែបើលោកអ្នកមិនដែលមានប្រវត្តិខ្ចីលុយសោះ ហើយហេតុផលនៃការបដិ

សេធនោះគឺប្រវត្តិជំពាក់លុយមិនគ្រប់គ្រាន់ ការទាក់ទង នឹង Reporting bureau មិនអាចជួយអីបានទេ ។

បន្ទាប់ពីពិនិត្យរបាយការណ៍ បើឃើញខុសលោកអ្នកត្រូវទាក់ទងនឹង Credit bureau ។ លោកអ្នកមានសិទ្ធិ និងចង្អុលបង្ហាញអំពីពត៌មានមិនពិតនោះ ហើយលើកយកមកដោះស្រាយ ។ ការចរចារដោះស្រាយជាការងាយស្រួលទេ តាមធម្មតាទូរស័ព្ទទៅសេវាបំរើភ្ញៀវ ដែលបានមកពីរបាយការណ៍នោះ ។ ភ្នាក់ងាររបស់ Reporting Credit នឹងទាក់ទងទៅម្ចាស់លុយដែលផ្តល់ពត៌មានមិនត្រឹមត្រូវនោះ ។ ក្នុងពេលពិនិត្យបើឃើញថាពត៌មានទាំងនេះពិតជាត្រឹមត្រូវ គេនឹងដាក់បញ្ចូលទៅវិញទៀត ។

បើមានរឿងយ៉ាងនេះកើតឡើងលោកអ្នកមានសិទ្ធិ សរសេរពន្យល់រហូតដល់ 100 ពាក្យទៅ Credit Reporting ពីរឿងរ៉ាវទាំងនេះ ។ ពេលដែលលោកអ្នកដាក់ពាក្យសុំខ្ចីលុយម្ចាស់លុយអាចជាពិនិត្យសំណុំរឿងរបស់លោកអ្នក ។

## តើខ្ញុំត្រូវធ្វើយ៉ាងណា ដើម្បីឲ្យបាន Credit ល្អនោះ ?

គោលកំនិតទាំង3ខាងក្រោមនេះ គឺសំរាប់រៀបចំ Credit ។ បើលោកអ្នកមានជោគជ័យក្នុងការរៀបចំគណនី ហើយមានការទទួលខុសត្រូវ ក្នុងរវាងពីមួយឆ្នាំទៅពីរឆ្នាំ លោកអ្នកនឹងអាចសាងសង់ប្រវត្តិ នៃការខ្ចីលុយយ៉ាងល្អ ។

## សុំជំនួយពីក្រុមហ៊ុន ក្នុងស្រុកដើម្បីបាន Credit ល្អ

ចាប់ផ្តើមពីធនាគារ Credit union ឬហាងលក់ទំនិញ ។ ត្រូវឲ្យប្រាកដថាក្រុមហ៊ុនទាំងនោះ នឹងធ្វើពត៌មានពីបញ្ជីនៃការជំពាក់លុយ ទៅការិយាល័យរបស់ Credit Reporting ខ្លះបើបានច្រើនកាន់តែល្អ ធ្វើយ៉ាងនេះអាចជួយឲ្យលោកអ្នកសាងសង់ប្រវត្តិជំពាក់លុយគេបានវិញ ។

**រកអ្នករ៉ាប់ធានា** ។ សុំឲ្យសាច់ញាតិ ឬមិត្តភក្តិដែលមាន Credit ល្អមកចុះហត្ថលេខាលើពាក្យសុំខ្ចីលុយ ។ អ្នករ៉ាប់ធានាត្រូវសន្យាថា នឹងសងជំនួសបើសិនជាលោកអ្នកមិនអាចសងបាន ។ បើលោកអ្នកមិនអាចសងគេតាមពេលកំណត់ អ្នកធានារ៉ាប់រងនោះត្រូវទទួលខុសត្រូវលើលុយជំពាក់គេនោះ ។ បើខកខានមិនសងគេ លោកអ្នកអាចបំផ្លាញ Credit របស់ញាតិឬមិត្តនោះ ។

## ប័ណ្ណខ្ចីលុយមានការធានា ។

ប័ណ្ណខ្ចីលុយមានការធានាគឺជាប័ណ្ណរបស់ធានាគារដែលមានលុយ ដែលលោកអ្នកយកទៅទុកក្នុងគណនីសំរាប់ ប្រើប្រាស់បើលោកអ្នកប្រើប័ណ្ណហើយមិនសងគេឲ្យអស់នោះគេនឹងដកយកលុយពីក្នុងគណនីទៅសងបំណុលនោះ ។ ត្រូវសាកសួរឲ្យបានច្រើនកន្លែង ដើម្បីឲ្យបានប័ណ្ណខ្ចីលុយមានការធានាប្រសើរមួយ។ លោកអ្នកអាចប្រៀបធៀបពត៌មានថ្មីៗ អំពីប័ណ្ណខ្ចីលុយនេះតាម www.bankrate.com ក្នុង Internet.។ មុននិងដាក់ពាក្យសុំត្រូវឲ្យដឹងច្បាស់ថាអ្នកដែលឲ្យប័ណ្ណនេះផ្ញើពត៌មានអំពីលុយនៅក្នុងគណនីទៅឲ្យ Credit Reporting Bureau ។ ត្រូវរកប័ណ្ណខ្ចីលុយមានការធានាដែលមាន

* បង់ប្រចាំឆ្នាំថោក
* គ្មានការបង់លុយមុនចូលជាសមាជិកដោយគ្មានគិតថ្លៃ
* បានការប្រាក់ពេលដាក់លុយ

## ប័ណ្ណខ្ចីលុយគ្មានការធានា

ក្រុមហ៊ុនជាច្រើនបានឲ្យប័ណ្ណគ្មានការធានា ទៅអ្នកដែលគ្មានប្រវត្តិជំពាក់លុយ ឬអ្នកខូច Credit ។

អាចមានការបង់ថ្លៃខ្ពស់ព្រោះភាគច្រើនមាន

* លុយដែលឲ្យខ្ចីមានចំនួនតិច

*ការប្រាក់ថ្លៃ

*ត្រូវបង់ថ្លៃការដាក់ពាក្យសុំ ការរៀបចំសុំណុំរឿង តាមធម្មតាត្រូវបង់ក្នុងសំបុត្រទារលុយលើកដំបូង

*បង់ថ្លៃចូលជាសមាជិកប្រចាំខែឬឆ្នាំ

*ត្រូវបង់លុយបើមានការឲ្យខ្ចីលុយបន្ថែមទៀត ។

បើលោកអ្នកចង់បានប័ណ្ណរបៀបនេះ ត្រូវយកពត៌មានឲ្យបានច្រើន ត្រូវប្រៀបធៀបការបង់ថ្លៃ fee និងការប្រាក់ ។ ដោយហេតុថាជួនកាលការបង់ fee ស្មើនិងកំរិតលុយដែលគេឲ្យខ្ចី ដូច្នេះលោកអ្នកប្រហែលជាគ្មានសល់លុយបំរុងទុករហូតទាល់តែបង់ Fees ។

## សេវានៃប័ណ្ណខ្ចីលុយដែលអាចជ្រើសរើសបាន

ក្រុមហ៊ុននៃប័ណ្ណខ្ចីលុយអាចផ្តល់សេវា និងលុយដោយគិតថ្លៃលើ

*ការធានារ៉ាប់រងចំពោះលុយដែលឲ្យខ្ចី ជាសេវាដែលជួយលោកអ្នកឲ្យបង់ចំនួនតិចប្រចាំខែ ក្នុងរយៈពេលខ្លីកាលបើលោកអ្នកមានជម្ងឺ ឬពិការ ។

*សេវាត្រួតពិនិត្យលុយឃ្លាំមើល Credit Report របស់លោកអ្នក ហើយផ្តល់ដំណឹងមកលោកអ្នកបើសិនបើមានការខើចលុយ ។

*ទស្សនាវតី នឹងសៀវភៅនៃប័ណ្ណចុះថ្លៃ

សេវាទាំងនេះអាចជ្រើសរើសបាន លោកអ្នកមិនចាំបាច់ទទួលយកទាំងអស់ទេ បើលោកអ្នកឆ្លើយទេពេលគេឲ្យជ្រើសរើស គ្មានការប៉ះពាល់ដល់ពាក្យសុំប័ណ្ណខ្ចីលុយឡើយ ។

## សិទ្ធិរបស់លោកអ្នក

The Fair Credit Reporting Act ជាច្បាប់របស់សហព័ន្ធដែលត្រួតត្រា Credit Reporting Bureau ហើយហាមប្រាមមិនឲ្យមានការផ្តល់ពត៌មានមិនត្រឹមត្រូវ ឬហួសសម័យដាក់ក្នុងបញ្ជីរបស់ Credit ។

លោកអ្នកមានសិទ្ធិ នឹងទទួល Credit Report ប្រចាំឆ្នាំដោយគ្មានគិតថ្លៃ ពីក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុន National Credit Reporting ទាំង 3 ។ ត្រូវមើល "How do I get my Credit Report? " ។ ពេលបានទទួលត្រូវពិនិត្យដោយប្រុងប្រយ័ត្ន ពីពត៌មានលេខកុង និងកំណត់នៃការសងប្រាក់ ។ ត្រូវឲ្យច្បាស់ថាកុងដែលបានបិទរួចទៅហើយត្រូវមានពាក្យ ចារថា " បិទតាមសំណើនៃអ្នកប្រើប្រាស់ " ។

លោកអ្នកមានសិទ្ធិ នឹងកែតំរូវពត៌មានមិនពិតនៅក្នុង Credit Report ។ ភ្ជាប់មកជា មួយ Credit Report មានលិខិតរៀបរាប់ថា ត្រូវធ្វើយ៉ាងណាកាលបើមានពត៌មាន មិនត្រឹមត្រូវ ឬអ្វីដែលលោកអ្នកមិនយល់ព្រម ។ ត្រូវតែតវ៉ាជានិច្ចកាលបើមាន ពត៌មានមិនត្រឹមត្រូវ ។

បន្ទាប់ពីលោកអ្នកធ្វើការតវ៉ា Credit bureau ត្រូវតែឆែកពិនិត្យប្រភពនៃពត៌មាន ហើយផ្ញើសេចក្តីកែតំរូវជាលើកចុងក្រោយមកឲ្យលោកអ្នក ។ តាមធម្មតាលោកអ្នកនិងបានទទួលចម្លើយក្នុងរយៈពេលពី 30ទៅ45ថ្ងៃ ។

ប៉ុន្តែបន្ទាប់ពីបានដំណឹងពីការិយាល័យនោះហើយមុនយល់ស្រប ត្រូវផ្ញើសេចក្តីថ្លែងការណ៍ 100 ពាក្យដែលនឹងបន្ថែមទៅក្នុង Credit Report របស់លោកអ្នកឲ្យបានទទួលដឹងឮបន្ថែមទៀត ។ច្បាប់ក៏ត្រួតត្រាលើពត៌មាននៃ Credit Report របស់លោកអ្នកដែរ ។ គណនីទាំង អស់ដែលលោកអ្នក បានសងរួចអស់ហើយ នឹងបង្ហាញនៅក្នុង Credit Report រហូតដល់ 10ឆ្នាំទោះជាសងទាំងអស់

ឬបិទលែងប្រើ ។ ពត៌មានពីបង់យឺត ឬមិន ទាន់សង នឹងនៅក្នុង Report របស់លោកអ្នកដល់ទៅ 7ឆ្នាំហើយការរកស៊ីខាត រលំអាចនៅក្នុង Report ដល់ទៅ 10ឆ្នាំ ។

## តើត្រូវតវ៉ាទៅឯណា ?

បើចង់ប្តឹងតវ៉ាពី Credit bureau ហាងលក់ឥវ៉ាន់ ឬ non – FDIC (Federal Deposit Insurance Corporation) ស្ថាប័នលុយដែលមានការធានា សុំសរសេរទៅ Consumer Response Center Federal Trade Commission ( FTC ), Washington DC 20580 ។ លោកអ្នកអាចប្តឹងតវ៉ា on line ទៅ FTC website ( www.ftc.gov ) ដើម្បីប្តឹងតវ៉ាពីម្ចាស់លុយ ឬក្រុមហ៊ុនប័ណ្ណខ្ចីលុយ សុំទូរស័ព្ទទៅក្រុមហ៊ុនហើយសួរឈ្មោះ និងអាស័យដ្ឋានរបស់ភ្នាក់ងារនោះ ។ ផ្ញើលិខិតប្តឹងតវ៉ាទៅក្រុមហ៊ុននោះហើយផ្ញើសេចក្តីចម្លងមួយច្បាប់ទៀតទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ចប់1